# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Mar-2012, 15:13
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើសុំស្តាប់ចម្លើយសាក្សីដែលត្រូវបានស្នើដោយមេធាវីការពារក្តី និង ចាត់ឲ្យមានវិធានការខាងនីតិវិធីដទៃទៀតដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវលើបរិបទប្រវត្តិសាស្ត្រ

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Jacqueline Greene (កម្មសិក្សាការីច្បាប់)

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“វិធានផ្ទៃក្នុង”) មេធាវីការពារ នួន ជា (“ក្រុមមេធាវីការពារក្តី”) តទៅនេះដាក់សំណើនេះ (“សំណើ”) ដោយស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង: (i) បន្តការពិភាក្សាលើផ្នែកប្រវត្តិសាស្ត្រនៃសវនាការវគ្គទីមួយ និង(ii) កោះហៅសាក្សី និងអ្នកជំនាញដែលបានស្នើឡើងដោយមេធាវីការពារក្តី[1] ដែលសក្ខីកម្មរបស់ពួកគេគឺពាក់ព័ន្ធសម្រាប់ការវាយតម្លៃ ឲ្យបានត្រឹមត្រូវលើបរិបទប្រវត្តិសាស្ត្រ។ សំណើនេះសង្កត់ធ្ងន់ថា ហេតុអ្វីបានជាមានការចាំបាច់ផ្នែកច្បាប់ដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាឲ្យបានទូលំទូលាយលើបរិបទប្រវត្តិសាស្ត្រ ទាក់ទងនឹងការឡើងកាន់អំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យ ស្របគ្នាជាមួយនិងវិធីសាស្ត្រដែលអនុវត្តដោយតុលាការអន្តរជាតិដទៃទៀត ។

## II. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់ញត្តិរបស់ខ្លួន “ដើម្បីគាំទ្រដល់ញត្តិ របស់ អៀង សារី សុំឲ្យដាក់បន្ថែមប្រធានបទថ្មីៗសម្រាប់សវនាការ ទៅក្នុងកម្មវិធីសវនាការ (“ញត្តិរបស់ អៀង សារី”)[2] និងសំណើសុំឲ្យបន្ថែមប្រធានបទថ្មីៗ។ នៅក្នុងញត្តិនេះមេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបន្ថែមប្រធានដូចខាងក្រោម (ដែលមកដល់បច្ចុប្បន្ន នេះនៅតែពាក់ព័ន្ធ) ទៅក្នុងកម្មវិធីសវនាការ: *បរិបទដែលពាក់ព័ន្ធ:* ប្រវត្តិសាស្ត្រភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ចសង្គម ប្រជាសាស្ត្រ យោធា និងច្បាប់និង/ឬស្ថាប័ន រួមទាំង

[1] បន្ថែមពីលើនេះអង្គជំនុំជម្រះសាលាដំបូងគប្បីពិចារណាឯកសារដែលពាក់ព័ន្ធនានាសម្រាប់ការវាយតម្លៃ ឲ្យបានត្រឹមត្រូវនៃបរិបទប្រវត្តិសាស្ត្រ ។

[2] ឯកសារលេខ E89, ញត្តិដើម្បីគាំទ្រដល់ដល់ញត្តិរបស់ អៀង សារី សុំឲ្យដាក់បន្ថែមប្រធានបទថ្មីៗសម្រាប់សវនាការទៅក្នុងកម្មវិធីសវនាការ និងសំណើឲ្យបន្ថែមប្រធានបទថ្មីៗ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ ERN 00699769-00699773។

បក្សកុម្មុនីស្តកម្ពុជាដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ប្រទេសកម្ពុជានៅមុនក្នុងអំឡុងពេល និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ[3]។

៣. នៅថ្ងៃទី៣ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបដិសេធចោលញត្តិនេះ ដោយបញ្ជាក់ថា "បញ្ហាបរិបទខាងប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍នានាដែលនៅក្រៅយុត្តាធិការពេលវេលារបស់ អវតក នឹងយកមកពិចារណា លុះត្រាណាតែហេតុការណ៍ និងបញ្ហាទាំងនោះជាប់ពាក់ព័ន្ធ ដោយផ្ទាល់ទៅនឹងបញ្ហាក្រោមយុត្តាធិការរបស់ អវតក និងវិសាលភាពនៃការជំនុំជម្រះប៉ុណ្ណោះ"[4]។ មកដល់ពេលនេះ ការពិចារណាយ៉ាងខ្លីនេះតំណាងឱ្យមូលហេតុទាំងមូលចំពោះការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនពិចារណាឱ្យបានទូលំទូលាយលើបរិបទប្រវត្តិសាស្ត្រនៅក្នុងអំឡុងពេលសវនាការ[5]។

៤. នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្តីផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងនូវសេចក្តីសង្ខេបបញ្ជីឈ្មោះសាក្សី ដែលក្នុងនោះក្រុមមេធាវីការពារក្តីបានដាក់ក្នុងបញ្ជីនូវបញ្ជីឈ្មោះសាក្សីចំនួន១៣២ នាក់ថាជាសាក្សីពាក់ព័ន្ធ ដើម្បីបង្កើតឱ្យបានត្រឹមត្រូវនូវបរិបទប្រវត្តិ

[3] នៅផ្នែកនេះត្រូវបញ្ចូលនូវអនុផ្នែកខាងក្រោម: ស្ថានភាពរស់នៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅពេលដែលបក្សកុម្មុនីស្តកម្ពុជាឡើងកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ និងអំឡុងពេលនៅមុនព្រឹត្តិការណ៍នេះ ។ វត្តមាន/ការពាក់ព័ន្ធរបស់បរទេសនៅកម្ពុជា រួមទាំងសកម្មភាពរបស់ភ្នាក់ងារចារកម្មណាមួយ-ជាពិសេសដែលជាការពាក់ព័ន្ធរបស់វៀតណាម ។ គោលបំណងជាវិជ្ជមានរបស់បក្សកុម្មុនីស្តកម្ពុជានៅមុនពេលក្តោបក្តាប់អំណាច ។ គោលបំណង និងអនុភាពនៃការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាដោយសហរដ្ឋអាមេរិកនៅទសវត្សទី៦០ និងដើមទសវត្សទី៧០ បើនិយាយពីការសម្លាប់ ការបំផ្លាញសម្ភារៈ (រួមទាំងផលប៉ះពាល់ដល់សមត្ថភាពផលិតស្បៀង) និងផលប៉ះពាល់ដល់លក្ខខណ្ឌរស់នៅ និងអារម្មណ៍របស់ប្រជាជនកម្ពុជានៅក្នុងតំបន់ដែលប៉ះពាល់ដោយការទម្លាក់គ្រាប់បែកនេះ។

[4] សូមមើលឯកសារ E93 "សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងនៅមុនពេលសវនាការបឋមពាក់ព័ន្ធទៅនឹងសាក្សីដែលភាគីស្នើសុំ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១១ ERN 00702332-00702333។

[5] សំណើនេះមិនមានបំណងលើកបញ្ហានេះឡើងវិញ ដូចដែលបានលើកឡើងនៅក្នុងឯកសារ E89/1 នោះទេ តែសំណើនេះគ្រាន់តែស្វែងរកការបង្ហាញដល់អង្គជំនុំជម្រះសាលាដំបូងថាភស្តុតាងដែលបានពិភាក្សានៅញត្តិ គឺ "ជាប់ពាក់ព័ន្ធទៅនឹងបញ្ហានានាដែលឋិតនៅក្រោមយុត្តាធិការរបស់ អវតក និងវិសាលភាពនៃការជំនុំជម្រះដែលកំណត់ដោយអង្គជំនុំជម្រះសលាដំបូង ហើយហេតុដូច្នេះអង្គហេតុដែលពិភាក្សាក្នុងអំឡុងពេលសវនាការដូចដែលកំណត់ដោយអង្គជំនុំជម្រះនៅក្នុងឯកសារ E93 ។ម្យ៉ាងវិញទៀត ការខកខានរបស់អង្គជំនុំជម្រះមិនបានផ្តល់មូលហេតុណាមួយនៅក្នុងការពិចារណាលើកដំបូងរបស់ខ្លួនលើបញ្ហាបរិបទប្រវត្តសាស្ត្រ បង្កើតឱ្យមានតម្រូវការខាងភស្តុតាងបន្ថែម ។

សាស្ត្រដែលពាក់ព័ន្ធ[6]។ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី[7]។ មិនមានសាក្សីណាម្នាក់ដែលស្នើឡើងដោយមេធាវីការពារក្តីដែលពាក់ព័ន្ធទៅនឹងការបង្កើតបរិបទប្រវត្តិសាស្ត្រ ត្រូវបានកោះហៅដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។ មកដល់ពេលនេះពុំមានភស្តុតាងបញ្ជាក់ថាអង្គជំនុំជម្រះមានចេតនាកោះហៅសាក្សីដែលស្នើដោយមេធាវីការពារក្តីឡើយ។ មកដល់ពេលនេះអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានផ្តល់មូលហេតុចំពោះសេចក្តីសម្រេចរបស់ខ្លួនក្នុងការមិនកោះហៅសាក្សីដែលស្នើឡើងដោយមេធាវីការពារក្តី[8]។

៥. ដូចដែលបានលើកឡើងនៅក្នុងសំណើផ្ទាល់មាត់ដោយចៅក្រម Cartwright នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់បញ្ជីឈ្មោះសាក្សីបន្ថែមទាក់ទងទៅនឹងបរិបទប្រវត្តិសាស្ត្រ[9]។ សាក្សីទាំងអស់ត្រូវបានដាក់បញ្ចូលក្នុងសំណើដើមរបស់មេធាវីការពារក្តីដែលដាក់ នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១[10]។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថាសំណើរបស់មេធាវីការពារក្តី "ខកខានមិនបានបង្ហាញថា ហេតុអ្វីមិនមានសាក្សីណាមួយក្នុងចំណោមពួកគេទាំង ៤៧នាក់ ត្រូវស្តាប់សក្ខីកម្មជាបន្ទាន់នោះទេ" ហើយដូច្នេះអង្គជំនុំជម្រះមិនស្តាប់សក្ខីកម្មរបស់សាក្សីណាមួយដែលស្នើឡើងនៅពេលនេះទេ[11]។

---

[6] ឯកសារ E9/10 សេចក្តីសង្ខេបពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើង ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ERN 00646349-00646443 ។ សាក្សីទាំងនេះត្រូវបានកំណត់អត្តសញ្ញាណថា អាចផ្តល់សក្ខីកម្មបានលើ "ស្ថានភាពនៅមុនឆ្នាំ១៩៧៥" ។

[7] ឯកសារ E31/1.1 ERN 00747479-00747481 ។

[8] ការមិនផ្តល់មូលហេតុនេះកើតចេញពីការដែលថា សាក្សីដែលស្នើឡើងដោយមេធាវីការពារក្តីមិនទាន់ត្រូវបានបដិសេធនៅឡើយទេ តែមេធាវីការពារក្តីត្រូវបានជូនដំណឹងក្រៅផ្លូវការដោយតំណាងរបស់អង្គជំនុំជម្រះសាលាដំបូងថា សាក្សីទាំងនេះនឹងមិនត្រូវបានគេកោះហៅនោះទេ ។

[9] ឯកសារ E155/1/.1 "បញ្ជីសាក្សីបន្ថែមទាក់ទងនឹងបរិបទប្រវត្តិសាស្ត្រ- ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា" ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១២។

[10] ឯកសារ E9/4.4 "បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្នើ" ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១១។

[11] នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ E172, ERN 00780657 "ត្រូវតែកត់សម្គាល់ថាមូលហេតុរបស់អង្គជំនុំជម្រះសាលាដំបូង គឺមិនទុកចិត្តបាន ។ មេធាវីការពារត្រូវបានបដិសេធនូវឱកាសដើម្បី

៦. នៅពេលឈានទៅដល់ការបញ្ចប់វគ្គសវនាការជំនុំជម្រះលើផ្នែកប្រវត្តិសាស្ត្រ វាហាក់ដូចជាច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងមានចេតនាកម្រិតខ្លួនឯងមកត្រឹមការវាយតម្លៃលើប្រធានបទដ៏មានកម្រិតនៃប្រវត្តិសាវតាររបស់បក្សកុម្មុយនីស្តកម្ពុជា[12] ដោយបានរំលងចោលការពិចារណា (និង/ឬដែលពាក់ព័ន្ធច្រើន) លើប្រធានបទដែលពាក់ព័ន្ធទៅវិញ ។ សារណានេះលើកអំណះអំណាងថា វិធីសាស្ត្របែបនេះ គឺមិនសមហេតុផល “បញ្ហា និងហេតុការណ៍ដែលមិនឋិតនៅក្រោមយុត្តាធិការពេលវេលារបស់ អវតក” ដែលមិនទាន់ត្រូវបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង ដែលតាមពិតទៅជាបញ្ហានិងហេតុការណ៍ដែលពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់ អវតក និងវិសាលភាពនៃការជំនុំជម្រះដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង”[13]។

## III. ច្បាប់ពាក់ព័ន្ធ

## ក. សារសំខាន់នៃបរិបទ

៧. តុលាការព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់សារៈសំខាន់លើវាយតម្លៃបរិបទទូទៅនៃជម្លោះ (ហើយដូច្នេះការវាយតម្លៃភស្តុតាង)។ នៅក្នុងរឿងក្តី *Tadić* នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

---

ផ្តល់មូលហេតុថា ហេតុអ្វីបានសាក្សីទាំងនោះ ត្រូវតែស្តាប់សក្ខីកម្ម ។ មេធាវីការពារក្តីបានព្យាយាមជាច្រើនដងក្នុងអំឡុងពេលសវនាការនៃថ្ងៃទី១៥ និងទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ មិនត្រូវបានអនុញ្ញាពីប្រធានតុលាការទេ ហើយប្រធានចៅក្រមជំនុំជម្រះថែមទាំងផ្តាច់ microphone របស់មេធាវីការពារក្តីទៀត ។ អាស្រ័យហេតុនេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះមិនស្តាប់សក្ខីកម្មរបស់សាក្សីទាំងនេះផ្អែកលើមូលដ្ឋានដែលថា មេធាវីការពារក្តីបានខកខានបង្ហាញពីភាពចាំបាច់របស់សក្ខីកម្មរបស់គេ ។ ចំពោះបញ្ហាដែលថាចៅក្រម Cartright ស្នើមេធាវីការពារក្តីដាក់សារណាជាលាយលក្ខណ៍អក្សរចំពោះមូលហេតុសម្រាប់ស្តាប់សក្ខីកម្មរបស់សាក្សី វាត្រូវតែកត់សម្គាល់ថាពេលវេលាតិចជា ២៤ ម៉ោងដែលកំណត់ដោយចៅក្រម Cartright សម្រាប់ដាក់សារណានេះ គឺជាជាមិនគ្រប់គ្រាន់ទេ ។

[12] មេធាវីការពារក្តីយល់ឃើញថាបើទោះបីការពិចារណាលើប្រធានបទដ៏កម្រិតនេះ បានប្រព្រឹត្តទៅក្នុងលក្ខណៈដ៏កម្រិតដោយការស្តាប់ (បន្ថែមពីលើការស្តាប់សក្ខីកម្មរបស់ នួន ជា) សក្ខីកម្មរបស់សាក្សីតែពីរនាក់ និងដើមបណ្តឹងរដ្ឋប្បវេណីតែពីរនាក់ ដែលពួកគេបានផ្តល់ព័ត៌មានដ៏កម្រិតបំផុតទាក់ទងនឹងប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជា។

[13] ឯកសារ E93 “សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងនៅមុនពេលសវនាការបឋមពាក់ព័ន្ធទៅនឹងសាក្សីដែលភាគីស្នើសុំ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១១ ERN 00702332-00702333:

សម្រាប់អតីតយូហ្គោស្លាវី("ICTY")[14] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងរឿងក្តី *Tadić* និយាយពីបរិបទទូទៅដែលមានកម្រាស់ ២៥ទំព័រ នៅក្រោមចំណងជើងថា *"បរិបទនៃជម្លោះ"*[15]។ វាផ្តល់ការវិភាគទូលំទូលាយពីប្រវត្តិសាស្ត្រនៅក្នុងតំបន់ និងប្រវត្តិសាស្ត្រដែលកើតឡើងជាច្រើនឆ្នាំមកហើយ។ នៅទូទាំងសាលក្រមទាំងមូលអង្គជំនុំជម្រះភ្ជាប់ហេតុការណ៍ជាប្របវត្តិសាស្ត្រទាំងនោះ ជាមួយនឹងអង្គហេតុនៃរឿងក្តី ។

៨. ចំណុចដែលគួរឱ្យកត់សម្គាល់នោះ ដើម្បីបង្កើតបរិបទប្រវត្តិសាស្រ្ត អង្គជំនុំជម្រះមិនផ្អែកទៅលើស្នាដៃសរសេររបស់អ្នកប្រវត្តិវិទូតែមួយទេ ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះក្នុងរឿងក្តី *Tadić* បានផ្អែករកឃើញរបស់ខ្លួនទាំងស្រុងលើសក្ខីកម្មដោយផ្ទាល់មាត់ដោយសាក្សីដាក់បន្ទុក និងសាក្សីដោះបន្ទុក[16]។

---

[14] រឿងក្តីរដ្ឋអាជ្ញា តទល់ *Tadić*, Case No. IT-94-1-T, មតិយោបល់ និងសាលក្រម ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៧ ។

[15] សូមមើល *Tadić* នៅជើងទំព័រ ១៤ ខាងលើ នៅកថាខណ្ឌ ៥៣-១២៦ (បញ្ជាក់បន្ថែម) ។ បន្ទាប់ពីបានផ្តល់ប្រវត្តិសាវតារទូទៅទាក់ទងនឹងជម្លោះ អង្គជំនុំជម្រះផ្តល់ការពន្យល់លម្អិតចំនួន ៥ ទំព័រ អំពីស្ថានភាពនៅក្នុងតំបន់ដែលបទបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត ។

[16] សូមមើល *Tadić* នៅជើងទំព័រ ១៤ ខាងលើ នៅកថាខណ្ឌ ៥៤ ។ សូមកត់សម្គាល់បន្ថែមទៀតទៀតថា ICTY គ្មាននឹងអវតក បានបទ្បញ្ញត្តិយ៉ាង តឹងរឹងទាក់ទងនឹងយុត្តាធិការពេលវេលា ។ តែវាក៏មិនបានបញ្ឈប់អង្គជំនុំជម្រះមិនឲ្យចំណាញពេលវេលា និងធនធានក្នុង ការស៊ើបអង្កេតហេតុការណ៍ដែលកើតឡើងដែរនៅក្រោមយុត្តាធិការពេលវេលា ។ មានហាក់ដូចជាមានន័យយ៉ាងច្បាស់ ថាតុលាការ ICTY ជ្រើសរើសវិធីសាស្ត្រនេះ ពិព្រោះ *Tadić* ជាសាលក្រមលើកដំបូងដែលចេញដោយតុលាការ ICTY ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចង់ផ្តល់ការពិពណ៌នាទូលំទូលាយនៃប្រវត្តិនៃជម្លោះដើម្បីដាក់ប្រវត្តិសាស្ត្រនេះនៅក្នុងករណីក្រោយៗទៀតនៅចំពោះតុលាការ ICTY ។ (ជាការពិតសាលក្រមរបស់ ICTY មិនមានផ្អែកយ៉ាងធំធេងពីបរិបទប្រវត្តិសាស្ត្រនោះទេ។ អវតក គប្បីជ្រើសយកវិធីសាស្ត្រស្រដៀងគ្នានេះ។ សម្រាប់មូលហេតុ ដែលបានបញ្ជាក់នៅក្នុងសារណានេះ ការពិភាក្សាពីប្រវត្តិសាស្ត្រត្រឹមត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា (ដូចដែល កសចស បានធ្វើរួចមកហើយនៅក្នុងដីកាដំណោះស្រាយ ហើយអង្គជំនុំជម្រះសាលាដំបូងក៏មានចេតនាធ្វើដែរ) គឺមិនគ្រប់គ្រាន់នោះទេ ដើម្បីបរិបទទូលំទូលាយនៃប្រវត្តិសាស្ត្រ ។ ករណី០០២ មិនដូចគ្នានឹងករណី ០០១ទេ ករណី ០០២ គឺជាករណីដំបូងគេដែលបរិបទប្រវត្តិសាស្ត្រ គឺពិតជាមានសារៈសំខាន់ដើម្បីយល់ដឹងឲ្យបានត្រឹមត្រូវលើអង្គហេតុនៃរឿងក្តីនេះ ។

៩. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ូហ្វាន់ដា ("ICTR") បានទទួលស្គាល់ស្រដៀងគ្នានេះ អំពីសារៈសំខាន់លើការវាយតម្លៃបរិបទទូទៅនៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ ។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *Akayesu* ជាករណីទីមួយដែលត្រូវសម្រេចនៅតុលាការ ICTR[17] បញ្ជាក់ពីសារៈសំខាន់នៃបរិបទ និងផ្តល់ប្រវត្តិសាស្ត្ររបស់ប្រទេស Rwanda "ចាប់ពីសម័យមុនអាណានិគម រហូតដល់ឆ្នាំ១៩៩៤"[18]។ អង្គជំនុំជម្រះនៅតុលាការ ICTR ក្នុងរឿងក្តី *Akayesu* រកឃើញថាការវិភាគទូលំទូលាយផ្នែកប្រវត្តិសាស្ត្រ "គឺចាំបាច់" ដើម្បីយល់អំពីហេតុការណ៍ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[19]។

## ខ. សិទ្ធិជាសារវន្តដើម្បីដាក់ជូនតុលាការនូវភស្តុតាងដោះបន្ទុក

១០. សិទ្ធិដើម្បីបង្ហាញភស្តុតាងដោះបន្ទុក ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ សិទ្ធិនេះចែងថាចុងចោទមានសិទ្ធិស្នើសុំឲ្យសាក្សីតាមរយៈគាត់ ឲ្យបង្ហាញភស្តុតាងដទៃទៀតដែលគាំទ្រដល់ទាមទារផ្នែកច្បាប់របស់គាត់ និងលើកឡើងការការពារក្នុងអំឡុងពេលសវនាការកាត់សេចក្តី ។

១១. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គាំទ្រដល់សិទ្ធិនេះនៅពេលដែលក្រមនេះទទួលស្គាល់សិទ្ធិរបស់ចុងចោទក្នុងការកោះហៅសាក្សីតាមរយៈគាត់ឲ្យផ្តល់ភស្តុតាង និងដាក់ជូនតុលាការនូវភស្តុតាងទាំងអស់ ដែលគាត់យល់ឃើញថាមានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត[20]។ ច្បាប់បង្កើត អវតក ទទួលស្គាល់សិទ្ធបង្ហាញភស្តុតាងដោះបន្ទុកដើម្បីធានា

---

[17] មូលហេតុសំខាន់ចែងនៅក្នុងជើងទំព័រ១៦។

[18] សូមមើលរឿងក្តីរដ្ឋអាជ្ញា តទល់ Akayesu ករណី ICTR-96-4-T "សាលក្រមចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ នៅកថាខណ្ឌ ៧៨, ៧៩ និង ១១១ ។

[19] សូមមើល *Akayesu* ជើងទំព័រ ១៨ ខាងលើ នៅកថាខណ្ឌ ៧៨។ កត់សម្គាល់ថាយុត្តាធិការពេលវេលារបស់តុលាការ ICTR កំហិតត្រឹមឆ្នាំ១៩៩៤ ។ បើទោះបីជាយ៉ាងនេះក្តីក៏វាមិនបានរារាំងអង្គជំនុំជម្រះក្នុងរឿងក្តី *Akayesu* ពីការពិចារណាបរិបទទូលំទូលាយនៃជម្លោះដែរ ហើយដូច្នេះ អង្គហេតុដែលកើតមុនឆ្នាំ១៩៩៤ ។

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៩៨ "ការកោះហៅសាក្សីតាមរយៈជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី- ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំងឡាយដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនឯងជាអ្នកចេញសោហ៊ុយ"។ សូមមើលផងដែរមាត្រា ៣៣៤ នៃក្រមនេះ "រហូតទល់នឹងការបិទកិច្ចពិភាក្សា

សិទ្ធិរបស់ជនជាប់ចោទ "ទទួលបានការនូវការចូលរួមនិងការពិនិត្យភស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានិងភស្តុតាងដាក់បន្ទុកដែរ" <u>សមស្របតាមសិទ្ធិទទួលបាននូវការធានាជាអប្បបរមាក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមអនុសញ្ញា ICCPR</u>[21] វិធានផ្ទៃក្នុងទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទដាក់បញ្ជីសាក្សីដែលពួកគេមានបំណងកោះហៅ[22]។

១២. សិទ្ធិរបស់ជនជាប់ចោទដើម្បីដាក់ជូនភស្តុតាងដោះបន្ទុក ក៏ត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិតាំងពីការជំនុំជម្រះនៅ Nuremberg[23]។ ICCPR[24] មានខ្លឹមសារដូចគ្នាប៉ះបិទនឹងអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស[25] និងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ចែងថាជនជាប់ចោទមានសិទ្ធិទទួលបានការចូលខ្លួន និងពិនិត្យសាក្សីជំនួសឲ្យគាត់។ ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមចែងបន្ថែម

---

ដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ថា មានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត"។

[21] ច្បាប់ អវតក មាត្រា ៣៥ថ្មី ។

[22] វិធាន ៨០(២) "នៅពេលដែលជនជាប់ចោទ និង/ឬ ក្រុមរួមគ្នានៃដើមបណ្តឹងរដ្ឋប្បវេណី មានបំណងកោះហៅសាក្សីណាម្នាក់ ដែលមិនមានឈ្មោះនៅក្នុងបញ្ជីដែលផ្តល់ឲ្យដោយសហព្រះរាជអាជ្ញា ត្រូវដាក់ជូនបញ្ជីឈ្មោះបន្ថែម [...]

[23] ធម្មនុញ្ញឡុងដុងនៃតុលាការយោធាអន្តរជាតិ, មាត្រា ១៦ "ដើម្បីធានាការកាត់សេចក្តីដោយយុត្តធម៌ដល់ជនជាប់ចោទនីតិវិធីខាងក្រោមនេះត្រូវតែអនុវត្ត:...ជនជាប់ចោទមានសិទ្ធិបង្ហាញភស្តុតាងដោះបន្ទុកតាមរយៈខ្លួនឯង ឬតាមរយៈមេធាវីនៅសវនាការ ដើម្បីគាំទ្រដល់ការពារខ្លួនគាត់... ។

[24] មាត្រា ១៤(៣) នៃ ICCPR: "នៅក្នុងការចោទប្រកាន់ប្រឆាំងខ្លួន ជនទាំងឡាយមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមាដូចខាងក្រោម មានស្មើគ្នាយ៉ាងពេញលេញ...(ង) ត្រូវមានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយសាក្សីដោះបន្ទុកចូលខ្លួនតាំងនាមគាត់ ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ។

[25] ECHR, មាត្រា ៦៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ "ជនទាំងឡាយណាដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋមានសិទ្ធិជាអប្បបរមាដូចខាងក្រោម...(ឃ)[...] ត្រូវមានការសួរចម្លើយឬសុំឲ្យសួរចម្លើយសាក្សីដោះបន្ទុកចូលខ្លួនតាំងនាមគាត់ ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ ។ សូមមើល *Vidal v. Belgium,* តុលាការអឺរ៉ុបសិទ្ធិមនុស្ស (២២ ខែមេសា ឆ្នាំ១៩៩២) ដោយបានរកឃើញថាសិទ្ធិរបស់ជនជាប់ចោទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមមាត្រា ៦ នៃ ECHR ត្រូវបានរំលោភនៅពេលដែលតុលាការបដិសេធដោយគ្មានមូលហេតុ ក្នុងការកោះហៅសាក្សីដែលស្នើដោយជនជាប់ចោទ ។

ទៀតថាសិទ្ធិរួមទាំងសិទ្ធិលើកឡើងការពារខ្លួន និងដាក់ជូនតុលាការនូវសាក្សីដោះបន្ទុក[26]។ ការសំដែងឱ្យឃើញនូវសិទ្ធិដាក់ជូនតុលាការនូវសាក្សីដោះបន្ទុក អាចរកបាននៅក្នុងយុត្តាធិការជាតិនៅទូទាំងពិភពលោក[27]។

១៣. សន្និទាននៅខាងក្រោយសិទ្ធិជាសារវ័ន្តនេះ គឺសាមញ្ញៈ ប្រសិនបើជនជាប់ចោទមិនត្រូវបានផ្តល់ឱ្យនូវសិទ្ធិដាក់ជូនតុលាការនូវសាក្សី និងភស្តុតាងរបស់គាត់ និងដើម្បីជំទាស់យ៉ាងមានប្រសិទ្ធិភាពទៅនឹងការចោទរបស់ព្រះរាជអាជ្ញានោះទេ តុលាការទទួលបានតែការបង្ហាញភស្តុ

[26] មាត្រា ៦៧(១)(ង) "ក្នុងការចោទប្រកាន់ពីបទឧក្រិដ្ឋ ជនជាប់ចោទមានសិទ្ធិទទួលការសួរដេញដោលជាសារធារណៈ ទទួលបានការជំនុំជម្រះទោសដោយឥតលំអៀង និងទទួលបានការធានាអប្បបរមា និងស្មើគ្នាយ៉ាងពេញលេញ... (ង) ត្រូវមានការសួរចម្លើយឬសុំឱ្យសួរចម្លើយសាក្សីដោះបន្ទុកចូលខ្លួនតាំងនាមគាត់ ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ ។ ជនជាប់ចោទក៏ត្រូវមានសិទ្ធិលើកឡើងការការពារខ្លួន និងដាក់ជូនតុលាការភស្តុតាងដទៃទៀតដែលអនុញ្ញាតដោយច្បាប់នេះ ចៅក្រម Jorda នៅតុលាការ ICC បានបញ្ជាក់ជូនជនជាប់ចោទអំពីសិទ្ធិរបស់គាត់ដើម្បីការពារខ្លួន ដោយកត់សង្កត់ធ្ងន់ថាជនជាប់ចោទមានសិទ្ធិស្នើសុំ និងពិនិត្យសាក្សី លើកឡើងនូវការការពារខ្លួន និងដាក់ជូនតុលាការនូវភស្តុតាងដទៃទៀតក្នុងអំឡុងពេលសវនាការ សមស្របតាមលក្ខន្តិកៈទីក្រុងរ៉ូម ។ រឿងក្តីរដ្ឋអាជ្ញា តទល់ *Lubanga Dyilo*, Case No. ICC-01/04-01/06, ប្រតិចារិតនៃការចូលខ្លួនលើកដំបូង (ខែមីនា ឆ្នាំ២០០៦) ។

[27] ការសំដែងឱ្យឃើញនូវសិទ្ធនេះ អាចរកឃើញនៅមាត្រា ២៨១ French Code de procédure pénale ដែលមិនត្រឹមតែផ្តល់ឱ្យជនជាប់ចោទនូវសិទ្ធិដាក់ជូនតុលាការនូវបញ្ជីឈ្មោះសាក្សីដោះបន្ទុកទេ តែថែមទាំងដាក់កាតព្វកិច្ចមកលើរដ្ឋអាជ្ញាឱ្យកោះហៅមេធាវីដោះបន្ទុកទាំងនេះទៀតផង "Le ministère public et la partie civile signifient à l'accusé, l'accusé signifie au ministère public et, s'il y a lieu, à la partie civile, dès que possible et vingt-quatre heures au moins avant l'ouverture des débats, la liste des personnes qu'ils désirent faire entendre en qualité de témoins. […] [L]e ministère public est tenu de citer à sa requête les témoins, dont la liste lui a été communiquée par les parties […]; cette liste ne peut comporter plus de cinq noms." ។ សូមមើលរឿងក្តី នៅ USA Taylor v. Illinois, 484 U.S. 400, 423-424 (1988) បានពិភាក្សាសារសំខាន់នៃសិទ្ធិដាក់ជូនតុលាការនូវសាក្សីដោះបន្ទុកនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអាមេរិក ។ សូមមើលផងដែរ New Zealand Bill of Rights Act, § 25(f), ទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទកោះហៅ និងពិនិត្យសាក្សី "ជនទាំងឡាយដែលត្រូវប្រកាន់ពីបទឧក្រិដ្ឋ មានសិទ្ធិ... ទទួលបានការចូលរួម និងពិនិត្យសាក្សីដោះបន្ទុកក្រោមលក្ខខណ្ឌដូចគ្នានឹងសាក្សីប្រឆាំងគាត់ដែរ ។ សូមមើល David S. Law & Mila Versteeg, The Evolution and Ideology of Global Constitutionalism, 99 Cal. L. Rev. 1163, 1201 (2011) ។

តាងមួយផ្នែក ឬភស្តុតាងស្នាទៗ ។ យុត្តិធម៌អាចធ្វើឲ្យបានសម្រេចក្នុងអំឡុងពេលសវនាការលុះណាតែការស្វែងរកការពិតត្រូវបានបំពេញ[28]។

## IV. អំណះអំណាង

## ក. សេចក្តីផ្តើម

១៤. របបកម្ពុជាប្រជាធិបតេយ្យមិនកើតឡើង និងប្រតិបត្តិនៅក្នុងលំហនោះទេ។ ហេតុការណ៍នានាដែលកើតឡើងនៅក្នុងរយៈកាលពីឆ្នាំ១៩៧៥-១៩៧៩ ជាប្រតិកម្មទៅនឹង (កើតចេញ) ពីហេតុការណ៍ដែលកើតឡើងមុនរយៈកាលនោះ។ អង្គជំនុំជម្រះសាលាដំបូងមិនអាចវាយតម្លៃតែសកម្មភាព (និងអំពើអកម្ម) របស់មេដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ ដោយពុំបានវាយតម្លៃឲ្យបានច្បាស់លាស់លើកាលៈទេសៈប្រវត្តិសាស្ត្រទូទៅ សង្គម និងនយោបាយដែលមានអនុភាពនៅពេលរបបកម្ពុជាប្រជាធិបតេយ្យក្តោបក្តាប់អំណាចទេ។ ភាពអត់ឃ្លាន ហាយនភាព ភាពក្រីក្រ ការស្លាប់ អំពើពុករលួយ ជំងឺ ភាពចលាចល និងកំហឹងនៅមុនការកកើតនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាកាលៈទេសៈអង្គហេតុដែលពាក់ព័ន្ធដល់មូលហេតុផ្នែកច្បាប់ និងត្រូវលើកមកពិភាក្សា[29]។

១៥. មេធាវីការពារក្តីយល់ឃើញថាប្រធានបទប្រវត្តិសាស្ត្រខាងក្រោមនេះ ដែលជាប់ពាក់ព័ន្ធគ្នាមិនអាចបំបែកបានជាមួយ (សកម្មភាព និងអំពើអកម្ម) របស់របបកម្ពុជាប្រជាធិបតេយ្យ ត្រូវតែលើកមកពិភាក្សានៅសវនាការជាធារណៈ ហើយសាក្សីត្រូវតែបានស្តាប់សក្ខីកម្មអំពី (i)កម្រិត និងអនុភាពនៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជាពី

---

[28] Taylor v. Illinois, 484 U.S. 400, 423-424 (1988) ការសំអាងផ្ទៃក្នុងត្រូវបានលុបៈ "សិទ្ធិមានលក្ខណៈជាសារវន្តច្រើនជាងសិទ្ធិរបស់ជនជាប់ចោទក្នុងដាក់ជូនតុលាការនូវសាក្សីជួសមុខឲ្យគាត់ ។ ការមិនដាក់បញ្ចូលភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌប៉ះពាល់គោលបំណងដ៏សំខាន់នៃការស្វែងរកការពិត... ពិតណាស់តម្លៃដ៏សំខាន់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់យើងលើការលើកលែងការចោទប្រកាន់ជនជាប់ចោទដែលគ្មានកំហុស" ។

[29] ចំនុចនេះមានការពិចារណាពិតៗ *fortiori* លើប្រធានបទនៃសវនាការវគ្គដំបូង "ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនដំណាក់កាលទីមួយ ដែលកើតឡើងនៅពេលចាប់ផ្តើមរបបកម្ពុជាប្រជាធិបតេយ្យ ។ កាលៈទេសៈដែលកើតឡើងនៅក្នុងប្រទេសកម្ពុជានៅមុនឆ្នាំ១៩៧៥ មានផលប៉ះពាល់ដោយផ្ទាល់ជាមួយព្រឹត្តហេតុទាំងនេះក្នុងលក្ខណៈជាច្រើន និងជាប់ពាក់ព័ន្ធ ។

ឆ្នាំ១៩៦៥ រហូតដល់ឆ្នាំ១៩៧៣ រួមទាំងការវាយតម្លៃការស្លាប់របស់ជនស៊ីវិល (ព្រមទាំងការធ្វើឲ្យពិការដល់កម្មករ និងការចុះថយសមត្ថភាពនៃការផលិត) និងការវាយតម្លៃការលើបំផ្លាញសម្ភារៈ ហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជា (ដូចជាផ្លូវថ្នល់បណ្តាញគមនាគមន៍ ទីកន្លែងផលិត។ល។), (ii) ការអត់ឃ្លាន និងភាពទុក្ខិក្សមួយផ្នែកធំនៃប្រទេសកម្ពុជា រួមទាំងទីក្រុងភ្នំពេញក្នុងអំឡុងខែមេសា ឆ្នាំ១៩៧៥ រួមទាំងការវាយតម្លៃចំនួនជនភៀសខ្លួននៅកម្ពុជា ស្ថានភាពរស់នៅរបស់ពួកគេ និងមូលហេតុដែលនាំឲ្យពួកគេបាត់បង់ទីជម្រក (iii)ភាពអាចរកបាននៃស្បៀង និងជាពិសេសអង្ករនៅទីក្រុងភ្នំពេញ និងនៅតំបន់នានានៃប្រទេសកម្ពុជានៅមុនខែមេសា ឆ្នាំ១៩៧៥ និងការវាយតម្លៃឲ្យបានត្រឹមត្រូវលើសមត្ថភាពផលិតកសិកម្មក្នុងរយៈពេលខ្លី និងរយៈពេលវែងនៅកម្ពុជានៅពេលនោះ (iv)ស្ថានភាពប្រព័ន្ធសុខាភិបាលនាខែមេសា ឆ្នាំ១៩៧៥ (v)ការវាយតម្លៃលើភាពអាចរកបានជំនួយមនុស្សធម៌របស់បរទេសក្នុងអំឡុងពេលឆ្នាំ១៩៧០-១៩៧៥ រួមទាំង (តែមិនកម្រិតត្រឹមតែ) ជំនួយរបស់ហរដ្ឋអាមេរិក ។

## ខ. ការពិចារណាលើបរិបទនេះ ត្រូវតែតម្រូវ សម្រាប់តែមូលហេតុផ្នែកច្បាប់ប៉ុណ្ណោះ

១៦. ការវាយតម្លៃត្រឹមត្រូវលើបរិបទប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ គឺចាំបាច់ដោយសារមូលហេតុផ្នែកច្បាប់ជាច្រើនដូចដែលពិភាក្សានៅខាងក្រោម។ ជារួម ការវាយតម្លៃត្រឹមត្រូវលើបរិបទទូទៅ គឺមិនអាចខ្វះបានឡើយដើម្បីវាយតម្លៃឲ្យបានគ្រប់គ្រាន់លើការពារខ្លួនដែលលើកឡើងដោយ នួន ជា (ឬគាត់មានបំណងលើក) ក្នុងពេលសវនាការ ព្រមទាំងការវាយតម្លៃលើកត្តាជំរុញផ្លូវចិត្ត និងចេតនានៅពីក្រោយសកម្មភាពរបស់គាត់ ។

### *១. ស្ថានភាពរបស់ប្រទេសក្រោយពីការផ្ទេរអំណាច គឺជាប់ព័ន្ធជាបឋម*

១៧. នៅកម្រិតមូលដ្ឋាន គេត្រូវតែកត់សម្គាល់ថានៅពេលមេដឹកនាំគ្រប់គ្រងប្រទេសមួយ ថាតើពួកគេកំពុងតែគ្រប់គ្រងប្រទេសដែលកំពុងតែដំណើរការទៅយ៉ាងល្អ និងជាប្រទេសមានវិបុលភាពដែរ ឬយ៉ាងណា ឬជាប្រទេសដែលស្ថិតក្នុងអន្លង់នៃភាពទុរភិក្សទៅហើយនោះ ជាមួយនឹងការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងស្រុង។ ដើម្បីវាយតម្លៃលើសកម្មភាព និងអំពើអកម្មរបស់មេដឹកនាំ គេត្រូវតែមានរូបភាពប្រត្យក្សពីស្ថានភាពរបស់ប្រទេសនៅពេលផ្ទេរ

អំណាច អាស្រ័យហេតុនេះការវាយតម្លៃបរិបទប្រវត្តិសាស្ត្រអាច (និង)ជាកត្តាបន្ធូរបន្ថយទោស ។

## ២. ការពិចារណាលើបរិបទនេះ ត្រូវតែតម្រូវ ដើម្បីការវាយតម្លៃឲ្យបានត្រឹមត្រូវលើអត្ថិភាពនៃ "មូលហេតុដែលអនុញ្ញាតក្រោមច្បាប់អន្តរជាតិ" សម្រាប់ការជម្លៀសប្រជាជន

១៨. ជាផ្នែកនៃការពិភាក្សារបស់ខ្លួនទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទីមួយ និងដំណាក់កាលទីពីរ កសចស បានពិចារណាយ៉ាងត្រឹមត្រូវថា តើការជម្លៀសប្រជាជនបានកើតឡើង "ដោយគ្មានមូលហេតុដែលអនុញ្ញាតដោយច្បាប់អន្តរជាតិដែរ ឬអត់"[30] ។ ដីកាដំណោះស្រាយចែងថា មេធាវីការពារជនជាប់ចោទ "បានលើកឡើងអំពីយុត្តិកម្មនានាដើម្បីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលពាក់ព័ន្ធទៅនឹងស្ថានភាពទូទៅនៅកម្ពុជានាសម័យកាលនោះ។ ជាបន្ទាប់ដីកាដំណោះស្រាយពិភាក្សា (និងបដិសេធ) យុត្តិកម្មជាច្រើនៈ សន្តិសុខរបស់ប្រជាជន ភាពចាំបាច់ខាងយោធា កង្វះស្បៀងនិង(កង្វះ)ថ្នាំសង្កូវ[31]។ ជាសរុប កសចស បដិសេធយុត្តិកម្មទាំងនេះដោយរកយល់ឃើញថា ការអះអាងរបស់ជនជាប់ចោទមិនមានទម្ងន់ ដោយមិនមានភស្តុតាងគាំទ្រ ។ និយាយម្យ៉ាងទៀត កសចស អះអាងថាបានពិចារណាយុត្តិកម្មដែលដាក់ដោយជនជាប់ចោទ ហើយបន្ទាប់មកបដិសេធយុត្តិកម្មទាំងនោះ ដោយមូលហេតុ ( កង្វះ) ភស្តុតាងក្នុងអំឡុងពេលស៊ើបសួរ ។

១៩. ការរកឃើញនូវអង្គហេតុនេះ (ការកង្វះខាតនូវភស្តុតាងដើម្បីគាំទ្រ និងក្នុងចំណោមបញ្ហាផ្សេងទៀត-ការអះអាងរបស់ នួន ជា) ពិតណាស់គឺគ្រាន់តែការវាយតម្លៃបឋមលើភស្តុតាងដោយ កសចស។ *នៅដំណាក់កាលសវនាការ* នៅពេលការកំណត់និយមន័យច្បាប់នៃអង្គហេតុ

---

[30] ដីកាដំណោះស្រាយ នៅកថាខណ្ឌទី១៤៤៩ ។ សំណួរសួរថា តើ កសចស បានអនុវត្តការវាយតម្លៃផ្នែកច្បាប់ដែរ ឬទេ នៅពេលពិចារណាបញ្ហានេះ ថាជាបញ្ហាសំខាន់មួយ ហើយនៅពេលដែលមេធាវីការពារក្តីឆ្លើយជាអវិជ្ជមាន ។ មេធាវីការពារក្តីយល់ឃើញថា កសព មានបន្ទុកបង្ហាញភស្តុតាងថាពុំមានមូលហេតុប្រឌិតដែលអនុញ្ញាដោយច្បាប់អន្តរជាតិកើតមាន ឬយកមកអនុវត្ត ។ ប៉ុន្តែ បញ្ហានេះមិនត្រូវបានឡើងនៅក្នុងសំណើនេះទេ ដោយសារវាមិនពាក់ព័ន្ធសម្រាប់ធ្វើអំណះអំណាងនោះឡើយ ។

[31] ដីកាដំណោះស្រាយ នៅកថាខណ្ឌទី១៤៥៣-១៤៦២ ។

ទាំងនេះ នឹងកើតឡើង នួន ជា ត្រូវតែផ្តល់ឱកាសដ៏មានប្រសិទ្ធិភាពដើម្បីជំទាស់ទៅនឹងការវាយតម្លៃបឋមដោយ កសចស ។

២០. មធ្យោបាយតែគត់ដែល នួន ជា អាចជំទាស់តវ៉ាយ៉ាងប្រសិទ្ធិភាពទៅនឹងការរកឃើញដោយ កសចស គឺអង្គជំនុំជម្រះសាលាដំបូងបម្រុងទុកពេលវេលាជាក់លាក់ក្នុងអំឡុងពេលសវនាការសម្រាប់ការពិភាក្សាលើ*ប្រធានបទពិសេសទាំងនេះ* ដែលត្រូវបានកំណត់ថា(ត្រឹមត្រូវ) ដោយ កសចស តាមរយៈការពិភាក្សា "មូលហេតុនានាដែលអនុញ្ញាតដោយច្បាប់អន្តរជាតិ")[32]។ ក្រៅពីការពិភាក្សាលើប្រធានទាំងនេះ នួន ជា ត្រូវតែបានអនុញ្ញាតឲ្យជំទាស់តវ៉ាទៅនឹងភស្តុតាងដែលផ្អែកដោយ កសចស[33] ហើយ នួន ជា ខ្លួនឯងត្រូវតែបានអនុញ្ញាតបង្ហាញភស្តុតាងដើម្បីគាំទ្រដល់ការអះអាងរបស់គាត់[34]។

២១. ទាក់ទងនឹងចំណុចក្រោយនេះ "ការពិចារណាលើការជំនុំជម្រះដោយយុត្តិធម៌ (ជាពិសេស សិទ្ធិដាក់ជូនតុលាការនូវភស្តុតាងដោះបន្ទុក) ព្រមទាំងការយល់ឃើញជារួមថា នួន ជា ត្រូវតែបានផ្តល់នូវឱកាសដ៏មានប្រសិទ្ធិភាព ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ទាក់ទងទៅនឹងភាពអាចមាន "មូលហេតុដែលអនុញ្ញាតដោយច្បាប់អន្តរជាតិ" គាត់ត្រូវតែផ្តល់ឱកាសបង្ហាញភស្តុតាងរបស់គាត់។ មានន័យថា នួន ជា ត្រូវតែផ្តល់ឱកាសដាក់ជូនទៅតុលាការនូវសាក្សី និងអ្នកជំនាញនានាដែលគាត់ស្នើទាន់ពេលវេលា និងដែលអាចគាំទ្រដល់ការអះអាងរបស់គាត់។ និយាយម្យ៉ាងទៀត ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងមានមូលដ្ឋានដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវលើសំណួរពាក់ព័ន្ធនានាដែលទាក់ទងទៅនឹងភាពអាចមានមូលហេតុសម្រាប់ការជម្លៀសប្រជាជន "ដែលត្រូវបានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ" ដូច្នេះការពិភាក្សាទូលំទូលាយលើ

---

[32] ប្រធានបទទាំងនេះ រួមទាំងសន្តិសុខរបស់ប្រជាជន ភាពចាំបាច់ផ្នែកយោធា កង្វះស្បៀងអាហារ និង(កង្វះខាត) សេវាសុខាភិបាល ។ សូមមើលកថាខណ្ឌ ១៨ ខាងលើ ។

[33] ក្នុងគំនិតរបស់ នួន ជា ភស្តុតាងដែលមិនអាចជឿទុកចិត្តបាន ។

[34] វាមិនត្រឹមតែ (តាមនិយមន័យ) "ការកំណត់ជាបឋម" នៃការរកឃើញរបស់ កសចស លើមូលដ្ឋានអង្គហេតុ "នៃមូលហេតុដែលអនុញ្ញាតដោយច្បាប់អន្តរជាតិ" ដែលត្រូវតែនាំឲ្យ នួន ជា មានឱកាសបង្ហាញភស្តុតាងការពារគាត់ប៉ុណ្ណឹងទេ តែមូលហេតុសផ្សេងទៀត គឺជាអង្គហេតុដែលថាការស៊ើបសួរដោយ កសចស *មិនគ្រប់គ្រាន់* ។ សូមមើលកថាខណ្ឌ ៣០ - ៣៩។

បរិបទប្រវត្តិសាស្ត្រទាក់ទងទៅនឹងការចូលកាន់កាប់របស់កម្ពុជាប្រជាធិបតេយ្យ គឺតម្រូវ ហើយដើម្បីអាចវាយតម្លៃបាន សាក្សី និងអ្នកជំនាញ ត្រូវតែបានស្តាប់សក្ខីកម្ម ។

### ៣. គោលគំនិតមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌតម្រូវឱ្យមានការពិភាក្សាស៊ីជម្រៅអំពីបរិបទ

២២. តាមទស្សនច្បាប់ព្រហ្មទណ្ឌជាមូលដ្ឋាន ករណីបរិបទទូលំទូលាយគឺមានការពាក់ព័ន្ធគ្នា។ ក្នុងរឿងក្តីព្រហ្មទណ្ឌណាក៏ដោយវាចាំបាច់ត្រូវតែពិចារណាអំពីហេតុផលដែលជនសង្ស័យ ជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តមួយចំនួន ហើយទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ការពិចារណានេះគឺមានសារៈសំខាន់ណាស់ដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវនូវ (១) ចេតនាដែលអាចកើតមានឡើង ឬការមិនមានចេតនា (២) ការដឹងឮ ឬការដឹងខ្លួនអំពីអង្គហេតុមួយចំនួន (៣) ហេតុផលដែលអាចកើតមានឡើង ឬច្រានចោលហេតុផលដែលបានចោទប្រកាន់ (៤) អំណះអំណាងសក្កានុពលសម្រាប់ការប្រព្រឹត្តមួយចំនួន និង (៥) កាលៈទេសៈសម្រាល ជាសក្កានុពល។

### ៤. ការវាយតម្លៃអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឱ្យមានការពិភាក្សាអំពីបរិបទ

២៣. ទោះបីជាការសង្កេតទាំងនេះគឺជាការពិតនៅក្នុងរឿងក្តីព្រហ្មទណ្ឌដទៃទៀត ប៉ុន្តែវាមិនមែនជារឿងត្រឹមត្រូវនោះទេក្នុងរឿងក្តីមួយ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ (ក៏ដូចជាបទប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មសង្គ្រាម)។ ប្រភេទឧក្រិដ្ឋកម្មទាំងអស់នេះពាក់ព័ន្ធយ៉ាងស្អិតទៅនឹងតថភាពផ្នែកសង្គមវិទ្យា នយោបាយ និងប្រវត្តិសាស្ត្រ ដូច្នេះគេមិនអាចវាយតម្លៃឱ្យបានត្រឹមត្រូវនូវហេតុផល និងចេតនារបស់ជនជាប់ចោទក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ដោយមិនបានធ្វើការពិនិត្យនៅពេលជាមួយគ្នាអំពីបរិបទប្រវត្តិសាស្ត្រទាក់ទងនឹងសកម្មភាព និងការសម្រេចចិត្តមួយចំនួន (ដូចជាការជម្លៀសប្រជាជនចេញពីទីក្រុងមួយចំនួនដោយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនៅពេលពួកគេគ្រប់គ្រងអំណាច)បានឡើយ។ និយាយដោយសាមញ្ញទៅ គេមិនអាចវាយតម្លៃពីចេតនា និងមូលហេតុរបស់លោក នួន ជា ដោយគ្រាន់តែធ្វើការពិចារណាអំពីសកម្មភាពរបស់គាត់នោះទេ។

ដើម្បីយល់ពីសកម្មភាពទាំងនេះឲ្យបានត្រឹមត្រូវ ចាំបាច់ត្រូវតែធ្វើការវាយតម្លៃដោយផ្អែកលើហេតុការណ៍ពិតជាប្រវត្តិសាស្ត្រ។

២៤. ជាងនេះទៅទៀត វាពាក់ព័ន្ធទៅនឹងបរិបទនៅ អវតក ដែលត្រូវកត់សម្គាល់ថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រាកដជាត្រូវបានប្រព្រឹត្តឡើងដោយផ្អែកលើមូលហេតុ "ជាតិ នយោបាយ ជាតិពន្ធ ពូជសាសន៍ ឬសាសនា"[35] ។ យោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហេតុផលនយោបាយ គឺជាហេតុផលពាក់ព័ន្ធសំខាន់បំផុតក្នុងការប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[36]។ ដើម្បីវាយតម្លៃឲ្យបានត្រឹមត្រូវអំពីហេតុផលនយោបាយ (ដែលមនុស្សភាគច្រើនអាចទទួលយកបាន) ទាំងនេះ វាចាំបាច់ត្រូវតែបង្កើតឲ្យមានការវាយតម្លៃឲ្យស៊ីជម្រៅ និងទូលំទូលាយអំពីបរិបទប្រវត្តិសង្គម និងនយោបាយដែលក្នុងនោះសកម្មភាព និងភាពអសកម្មរបស់តួអង្គពាក់ព័ន្ធបានកើតឡើង។

## ៥. ការវាយតម្លៃអំពីការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយតម្រូវឲ្យមានការពិភាក្សាអំពីបរិបទ

២៥. ដូចគ្នានេះដែរ នៅពេលធ្វើការវាយតម្លៃអំពីឧក្រិដ្ឋកម្ម នៃការ "ធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ" ដែលលោក នួន ជា ត្រូវបានចោទប្រកាន់[37] គេមិនអាចជៀសវាងការពិចារណាឲ្យបានស៊ីជម្រៅនូវកាលៈទេសៈប្រវត្តិសាស្ត្រ នយោបាយ និងសង្គមបានឡើយ។ នេះគឺជាការ

---

[35] ច្បាប់ អវតក មាត្រា ៥។

[36] ដីកាដំណោះស្រាយ, កថាខណ្ឌ១៤១៥ ដល់១៣៦៦, ១៣៦៨ ដល់១៤២៥ (ដែលបង្កើតបានជាផ្នែកមួយនៃសវនាការវគ្គទី១)។

[37] ដីកាដំណោះស្រាយ, កថាខណ្ឌ១៤១៥ ដល់១៤១៨, ១៤២៣ ដល់១៤២៥(ដែលបង្កើតបានជាផ្នែកមួយនៃសវនាការវគ្គទី១)។ ពិតណាស់នៅពេលមានការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ និងលក្ខខណ្ឌតម្រូវនៃចេតនាពិសេសរបស់វា វាចាំបាច់ត្រូវតែមានការពិពណ៌នាដោយផ្អែកលើប្រវត្តិសាស្ត្រឲ្យបានស៊ីជម្រៅអំពីបរិបទទូលំទូលាយនៃសកម្មភាព និងភាពអសកម្មរបស់តួអង្គដែលពាក់ព័ន្ធ និងស្ថានភាពប្រវត្តិសង្គមឲ្យបានត្រឹមត្រូវ។ យើងនឹងមិនលើកយកចំនុចនេះមកវែកញែកបន្ថែមទៀតក្នុងសំណើនេះទេព្រោះបទចោទប្រកាន់អំពីបទប្រល័យពូជសាសន៍មិនបង្កើតបានជាផ្នែកមួយនៃសវនាការ វគ្គទីមួយនេះឡើយ។

ពិតជាពិសេសនៅពេលពីចារណាពីការធ្វើទុក្ខបុកម្នេញដែលគេចោទថាបានប្រព្រឹត្តឡើង ដោយផ្អែកលើហេតុផលនយោបាយ[38]។ ដូច្នេះ ដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវអំពីចេតនារបស់លោក នួន ជា ទាក់ទងនឹងការចោទប្រកាន់ពីបទធ្វើទុក្ខបុកម្នេញ ការវាយម្លៃដ៏ធំលំទូលាយអំពីបរិបទនយោបាយ ប្រវត្តិសាស្ត្រ និងសង្គមនៃសកម្មភាពរបស់លោក នួន ជា ចំបាច់ត្រូវតែធ្វើឡើង[39]។

***៦.ការវាយតម្លៃយ៉ាងត្រឹមត្រូវអំពីសហឧក្រិដ្ឋកម្មរួម រួមបញ្ចូលទាំងគោលបំណង និងការអនុវត្តគោលនយោបាយរួម តម្រូវឱ្យមានការវាយតម្លៃបរិបទឱ្យបានទូលំទូលាយជាងនេះ***

២៦. ដីកាដំណោះស្រាយក្នុងផ្នែកដែលនិយាយអំពីការរកឃើញអង្គហេតុស្តីអំពីសហឧក្រិដ្ឋកម្មរួម ("JCE") លើកឡើងថា "គោលបំណងរួមនៃ (JCE) បានកើតឡើងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ឬមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ គោលនយោបាយទាំង៥ (ប្រាំ) ដែលធ្វើឡើងដើម្បីសម្រេចផែនការរួមនេះ ត្រូវបានអនុវត្តនៅក្នុងរវាង ឬមុនកាលបរិច្ឆេទទាំងនេះ"[40]។ យោងតាមការិយាល័យសហចៅក្រមស៊ើបអង្កេត គោលបំណងរួមនៃ (JCE) "គឺដើម្បីអនុវត្តបដិវត្តសង្គមនិយមយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជាតាមរយៈគ្រប់មធ្យោបាយចាំបាច់តាម "សន្ទុះមហា

---

[38] ឧទាហរណ៍ ករណីនេះត្រូវបានបង្ហាញនៅពេលដែលដីកាដំណោះស្រាយបាននិយាយអំពីមន្ត្រីថ្នាក់ទាបនៃរបបលន់ណុល ដែលត្រូវបានចាប់ខ្លួនភ្លាមៗនៅពេលដែលកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាចដោយសារតែមន្ត្រីទាំងនោះ មានជាប់ពាក់ព័ន្ធទៅនឹងរដ្ឋាភិបាលមុនៗ។ ករណីនេះនាំឱ្យមានជាសំណួរថាតើ "របបមុន" ជាអ្វី? ហើយហេតុអ្វីបានជា ការជាប់ពាក់ព័ន្ធជាមួយរដ្ឋាភិបាលនេះផ្តល់ហេតុផលនៃការចាប់ខ្លួន។ ម្យ៉ាងវិញទៀត បរិបទនយោបាយត្រូវការជាចាំបាច់ដើម្បីយល់ និងវាយតម្លៃឱ្យបានត្រឹមត្រូវនូវបទចោទទាំងនេះ។

[39] ដកស្រង់ចេញពីដីកាដំណោះស្រាយស្តីពីបញ្ហានេះ "ពាក់ព័ន្ធនឹងបំណងឧក្រិដ្ឋ ចេតនាក្នុងការរើសអើងដោយហេតុផលពូជសាសន៍ នយោបាយ ឬសាសនា ត្រូវបានបង្ហាញក្នុងបរិបទនៃការវាយប្រហារ និងកាលៈទេសៈជុំវិញការអនុវត្តសកម្មភាព"។ (ដីកាដំណោះស្រាយ កថាខណ្ឌ១៥២៣)។ មេធាវីការពារក្តីយល់ឃើញថា "បរិបទ" និង "កាលៈទេសៈ" នៅជុំវិញការប្រព្រឹត្តទង្វើផ្សេងៗ គឺពិតជាមានការពាក់ព័ន្ធ ហើយបើតាមកត្តវិជ្ជាវាមិនត្រូវកំណត់ពេលវេលាត្រឹមពីឆ្នាំ១៩៧៥ ដល់១៩៧៩ ឡើយ។

[40] ដីកាដំណោះស្រាយ, កថាខណ្ឌ១៥៨ (គូសបញ្ជាក់បន្ថែម)។

លោតផ្លោះ " និងដើម្បីការពារប្រឆាំងនិងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ"[41]។ ដូច្នេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលស្គាល់យ៉ាងច្បាស់ថា ឬសគុលដែលនាំឱ្យ មាន ផែនការរួមនៃសហឧក្រិដ្ឋកម្មរួមដែលបានចោទប្រកាន់[42] បានកើតឡើងនៅមុនខែមេសា ឆ្នាំ ១៩៧៥ ទៅទៀត។ ការិយាល័យសហចៅក្រមស៊ើបអង្កេតក៏បានទទួលស្គាល់ផងដែរថា ឫសគុលដែលនាំឱ្យមានគោលនយោបាយទាំងប្រាំដែលធ្វើឡើងដើម្បីសម្រេចគោលបំណង រួមនេះ ក៏បានកើតឡើងមុនខែ មេសា ឆ្នាំ ១៩៧៥ ផងដែរ។

២៧. ដូចដែលការិយាល័យសចៅក្រមស៊ើបអង្កេតបានលើកឡើង ជាការពិតណាស់ថាប្រសិនបើ គោលបំណងរួមដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សក្នុងប្រទេសកម្ពុជា និងដើម្បី ការពារបក្សប្រឆាំនឹងសត្រូវផ្ទៃក្នុង និងសត្រូវខាងក្រៅ បានកើតឡើង *មុន* ខែមេសា ឆ្នាំ ១៩៧៥ តុលាការនេះត្រូវតែវាយតម្លៃអំពីកាលៈទេសៈប្រវត្តិសាស្ត្រ និងសង្គម *មុន* ខែមេសា ឆ្នាំ១៩៧៥ ដែលក្នុងនោះគោលបំណងរួមត្រូវបានអនុវត្តយ៉ាងពេញលេញ[43]។ ដូចគ្នានេះដែរ ប្រសិនបើគោលនយោបាយមួយចំនួនដើម្បីសម្រេចគោលបំណងរួមខាងលើនេះត្រូវបានអនុវត្ត រួចស្រេចហើយនៅមុន ខែ មេសា ឆ្នាំ ១៩៧៥ វាច្បាស់ណាស់ថាតុលាការនេះ ចាំបាច់ត្រូវតែ ក្រឡេកមើលទៅរយៈពេលមុន ខែមេសា ឆ្នាំ១៩៧៥ ដើម្បីបង្កើតបានជាមូលដ្ឋានហេតុផល សមស្របដើម្បីវាយតម្លៃពីការអនុវត្តគោលនយោបាយ (ដែលមនុស្សភាគច្រើនអាចទទួលយក បាន) ខាងលើ។ ម្យ៉ាងវិញទៀត ការវាយតម្លៃយ៉ាងត្រឹមត្រូវអំពីទិដ្ឋភាពនៃ (JCE) តម្រូវឱ្យ មានការពិចារណាឱ្យបានទូលំទូលាយអំពីបរិបទប្រវត្តិសាស្ត្រដែលនៅពេលនោះរបបកម្ពុជា ប្រជាធិបតេយ្យបានឡើងកាន់អំណាច។

---

[41] ដីកាដំណោះស្រាយ, កថាខណ្ឌ១៥៦។

[42] លោក នួន ជា ជំទាស់ទៅនឹងអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម។ នៅក្នុងសំណើនេះ មេធាវីការពារក្តីនឹងមិនលើកឡើង ពីបញ្ហានេះបន្ថែមទៀតឡើយ។

[43] នេះជាការពិតមិនមែនគ្រាន់តែដោយសារតែដីកាដំណោះស្រាយបានអះអាងថាព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ គឺជាឫសគុល នៃគោលបំណងរួមប៉ុណ្ណោះទេ ប៉ុន្តែក៏ដោយសារតែផែនការរួមមានទំនាក់ទំនងយ៉ាងស៊ីសង្វាក់គ្នាទៅនឹងការគិតពិចារណា ដល់សង្គមៈ បើនិយាយដល់ការលើកឧទ្ទាហរណ៍ ប្រសិនបើគេសន្មត់ថាគោលបំណងរួមរបស់បក្សកុម្មុនីស្ត កម្ពុជា គឺជាការ អនុវត្តឱ្យបានឆាប់រហ័សនូវបដិវត្តន៍សង្គមនិយមក្នុងប្រទេសកម្ពុជា គេមិនអាចជៀសផុតពីការពិចារណា អំពីបញ្ហាដែល ទាក់ទងនឹងកាលៈទេសៈសង្គមដែលនាំឱ្យមេដឹកនាំកម្ពុជាប្រជាធិបតេយ្យចង់អនុវត្តបដិវត្តន៍សង្គមនិយម បែបនេះឡើយ។

## ៧. ការតម្រូវឲ្យមានការវាយតម្លៃទូលំទូលាយអំពីបរិបទបណ្តាលដោយផ្ទាល់ មកពីការចោទប្រកាន់មួយចំនួន

២៨. ជាងនេះទៅទៀត ស្ថានភាពមុនឆ្នាំ១៩៧៥ សមនឹងទទួលបានការចាប់អារម្មណ៍យ៉ាងពេញលេញពីតុលាការព្រោះដីកាបញ្ជូនរឿងឲ្យស៊ើបសួរមានបទចោទមួយចំនួនពាក់ព័ន្ធយ៉ាងសមហេតុផលទៅនឹងរយៈពេលមុនឆ្នាំ១៩៧៥ ដូចជាការចោទប្រកាន់ដែលថា លោក នួន ជា បានដកហូតពីប្រជាជននូវជំនួយផ្នែកវិជ្ជសាស្ត្រ ទីជំរក អាហារ និងស្ថានភាពអនាម័យអប្បបរមា ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ (ដំណាក់កាលទី១)[44]។ ដើម្បីវាយតម្លៃការចោទប្រកាន់នេះឲ្យបានត្រឹមត្រូវ វាចាំបាច់ត្រូវតែបង្កើតការវិភាគឲ្យបានស៊ីជម្រៅ និងត្រឹមត្រូវអំពីបរិមាណស្បៀងជាទូទៅនៅក្នុងប្រទេសកម្ពុជា និងជាពិសេសក្នុងទីក្រុងភ្នំពេញមុន ខែមេសា ឆ្នាំ១៩៧៥ ក៏ដូចជាស្ថានភាពទូទៅនៃសេវាវេជ្ជសាស្ត្រ និងស្ថានភាពអនាម័យក្នុងប្រទេសកម្ពុជា និងក្នុងទីក្រុងភ្នំពេញ[45]។ ម្យ៉ាងវិញទៀត បរិបទទូលំទូលាយនៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាចត្រូវតែធ្វើការត្រួតពិនិត្យដើម្បីវាយតម្លៃការចោទប្រកាន់នេះឲ្យបានត្រឹមត្រូវ។

## ៨. ការវាយតម្លៃឲ្យបានទូលំទូលាយជាងនេះអំពីបរិបទគឺជាការចំបាច់ ដើម្បីវាយតម្លៃឲ្យបានពេញលេញនូវការអះអាងពីភាពចាំបាច់

២៩. លោក នួន ជា និងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ បានរែកញែកថាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញគឺចាំបាច់ដើម្បីសង្គ្រោះប្រជាជនឲ្យចាកផុតពីភាពអត់ឃ្លាន និងដើម្បីការពារពួកគេពីការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកដែលពួកគេបារម្ភថាទីក្រុងភ្នំពេញគឺជាទិសដៅនៃការវាយប្រហារនេះ។ ពួកគេក៏បានអះអាងផងដែរថាការជម្លៀសប្រជាជនដ៏ទៃទៀតគឺដើម្បីធ្វើឲ្យប្រជាជនមានអាហារបរិភោគគ្រប់គ្រាន់ និង/ឬដើម្បីបង្កើនការផលិត

---

[44] ដីកាដំណោះស្រាយ, កថាខណ្ឌ១៤៣៥ (ដែលបង្កើតបានជាផ្នែកមួយនៃសវនាការវគ្គទី១)

[45] និយាយដោយសាមញ្ញ ប្រសិនបើមិនមានស្បៀងនៅក្នុងប្រទេស ឬក្នុងទីក្រុងទេ មនុស្សម្នាក់មិនអាចត្រូវបានគេចាត់ ទុកជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌដោយសារតែមិនផ្តល់ស្បៀងនោះទេ។

ស្បៀង។ តាមន័យច្បាប់ការអះអាងបែបនេះគឺជាអះអាងអំពីភាពចាំបាច់[46]។ ថាតើនៅពេលនេះអង្គជំនុំជម្រះសាលាដំបូងចាត់ទុកការអះអាងបែបនេះថាសមហេតុផល ឬអត់នោះ វាល្មមគ្រប់គ្រាន់ទៅហើយដើម្បីធ្វើការសង្កេតថាការលើកឡើងបែបនេះគឺជាផ្នែកមួយនៃការពន្យល់របស់លោក នួន ជា អំពីហេតុផលនៃសកម្មភាពរបស់គាត់។ វិធីដែលសមរម្យតែមួយគត់ដើម្បីវាយតម្លៃ ថាតើលោក នួន ជា ពឹងផ្អែកលើការការពារពីភាពចាំបាច់ ឬអត់នោះ គឺត្រូវគិតពិចារណាឲ្យបានស៊ីជម្រៅអំពីស្ថានភាពប្រទេស ជាពិសេសស្ថានភាពក្នុងទីក្រុងភ្នំពេញក្នុងអំឡុងពេលមុនខែ មេសា ឆ្នាំ ១៩៧៥។ម្យ៉ាងវិញទៀត ជាថ្មីម្តងទៀត បរិបទដ៏ទូលំទូលាយនៅពេលដែលរបបកម្ពុជាប្រជាធិតតេយ្យឡើងកាន់អំណាចត្រូវតែយកមកពិចារណា[47]។

**គ. ឥឡូវនេះ ការខកខានរបស់ កសចស និង កសព ក្នុងការស៊ើបអង្កេត បានរារាំងមេធាវីការពារក្តីមិនឲ្យផ្តល់ភស្តុតាងគាំទ្រដល់ការអះអាងរបស់ខ្លួន**

៣០. មកទល់សព្វថ្ងៃនេះ រចនាសម្ព័ន្ធច្បាប់នៅ អវតក បានបដិសេធដោយប្រសិទ្ធិភាពនូវឱកាសរបស់មេធាវីការពារក្តីដើម្បីផ្តល់ភស្តុតាងគាំទ្រដល់ការអះអាងរបស់លោក នួន ជា ទាក់ទងនឹងស្ថានភាពប្រទេសកម្ពុជានៅពេលមានការផ្លាស់ប្តូរអំណាចក្នុង ខែមេសា ឆ្នាំ១៩៧៥ និងមូលហេតុពាក់ព័ន្ធនៃសកម្មភាពរបស់គាត់។ ការផ្តល់ភស្តុតាងគាំទ្របែបនេះដោយមេធាវីការពារក្តី ត្រូវបានរារាំងព្រោះរហូតមកទល់ពេលនេះ មិនមានការស៊ើបអង្កេតគ្រប់គ្រាន់ណាមួយ

---

[46] ការការពារពីភាពចំបាច់ គឺជាការការពារដែលបានបង្កើតឡើងយ៉ាងប្រសើរនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយត្រូវបានទទួលស្គាល់ដោយច្បាប់កម្ពុជា (សូមមើលមាត្រា៩៧(២) នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦)។ ដូច្នេះការការពារនេះត្រូវតែវាយតម្លៃឲ្យបានទូលំទូលាយដោយអង្គជំនុំជម្រះសាលាដំបូងនៅពេលដែលបញ្ហានេះត្រូវបានលើកឡើងដោយ ចុងចោទ។

[47] នៅពេលដែលសំណើនេះលើកឡើងក្នុងកថាខណ្ឌ១៦ ដល់ ២៩ ថាបរិបទទូលំទូលាយត្រូវតែយកមកពិចារណា ករណីនេះ ក៏មានន័យផងដែរថាលោក នួន ជា ត្រូវតែទទួលបានឱកាសដើម្បីផ្តល់ភស្តុតាងគាំទ្រការអះអាងរបស់គាត់ទាក់ទងទៅនឹងបរិបទទូលំទូលាយនេះ។ សូមមើលជើងទំព័រខាងក្រោម។ សូមមើលផងដែរត្រង់ករថាខណ្ឌ១៩ ដល់ ២១។

ត្រូវបានធ្វើឡើងដោយ កសចស ឬ កសព ទៅក្នុងបរិបទប្រវត្តិសាស្ត្រដែលរបបកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាចឡើយ[48] ហើយមេធាវីការពារក្តីមិនត្រូវបានគេអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯងដែរ[49]។

### ១. កសចស ខកខានមិនបានស៊ើបអង្កេតឲ្យបានគ្រប់គ្រាន់នូវបញ្ហាសំខាន់មួយចំនួន

៣១. ការស៊ើបអង្កេតរបស់ កសចស បានផ្តោតតែលើឧក្រិដ្ឋកម្មដែលគេចោទថាជនជាប់ចោទបានប្រព្រឹត្តតែប៉ុណ្ណោះ។ កសចស ខកខានមិនបានស៊ើបអង្កេតឲ្យបានគ្រប់គ្រាន់នូវធាតុផ្សំបរិបទពាក់ព័ន្ធដ៏ទូលំទូលាយ សំខាន់បំផុតនោះគឺស្ថានភាពក្នុងប្រទេសកម្ពុជា និងក្នុងក្រុងភ្នំពេញមុនខែ មេសា ឆ្នាំ ១៩៧៥។ ដំណោះស្រាយដែលមានកំហុសឆ្គងនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់ដោយការប្រព្រឹត្តរបស់ កសចស ក្នុងដីកាដំណោះស្រាយទាក់ទងនឹងប្រធានបទសំខាន់ៗ និងមានទំនាក់ទំនងគ្នាចំនួនពីគឺ ស្ថានភាពនៅក្នុងទីក្រុងភ្នំពេញមុន ខែមេសា ឆ្នាំ១៩៧៥ និងការទម្លាក់គ្រាប់បែករបស់អាមេរិកមកលើប្រទេសកម្ពុជាចន្លោះពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧៣។

#### *ក. ការពិពណ៌នារបស់ កសចស អំពីទីក្រុងភ្នំពេញក្នុង ខែមេសា ឆ្នាំ១៩៧៥*

៣២. ការយល់មិនគ្រប់ជ្រុងជ្រោយរបស់ កសចស អំពីសារៈសំខាន់នៃបរិបទដ៏ទូលំទូលាយ ត្រូវបានស្តែងឲ្យឃើញក្នុងការពិភាក្សាក្នុងដីកាដំណោះស្រាយអំពីស្ថានភាពដ៏គួរឲ្យរន្ធត់ក្នុងទីក្រុងភ្នំពេញមុនខែ មេសា ឆ្នាំ ១៩៧៥។ ស្ថានភាពក្នុងទីក្រុងភ្នំពេញ ត្រូវបានពិពណ៌នាមិនលើសពីបីកថាខណ្ឌខ្លីៗនោះឡើយ ហើយគួរឲ្យភ្ញាក់ផ្អើលថែមទៀតនោះ កថាខណ្ឌទាំងនេះបានលាបពណ៌ទៅលើស្ថានភាពក្នុងទីក្រុងភ្នំពេញមុនខែ មេសា ឆ្នាំ ១៩៧៥[50]។

៣៣. ការពិនិត្យមើលស្ថានភាពក្នុងទីក្រុងភ្នំពេញតែក្នុងបីកថាខណ្ឌខ្លីៗ (ជាផ្នែកមួយនៃដីកាដំណោះស្រាយដែលមានចំនួន៣៩៨ទំព័រសំខាន់ៗ) មិនបានផ្តល់យុត្តិធម៌ដល់សារៈសំខាន់នៃប្រធាន

---

48 បរិបទនេះ រួមបញ្ចូលទាំង ប៉ុន្តែមិនកំរិតត្រឹម ស្ថានភាពដ៏គួរឲ្យរន្ធត់ក្នុងទីក្រុងភ្នំពេញ និងក្នុងប្រទេសកម្ពុជាទាំងមូលនៅពេលនោះឡើយ។

49 សូមមើលឯកសារ **A110/1** លិខិតរបស់ កសចស ទៅកាន់ក្រុមការពារក្តីលោក នួន ជា, ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៨, A1101, ERN 00157730។

50 ដីកាដំណោះស្រាយ, កថាខណ្ឌ២២១ ដល់២២៣។

បទនេះឡើយ។ សំខាន់ជាងនេះទៅទៀត កថាខណ្ឌខ្លីៗទាំងនេះ គឺមានកំហុសខាងអង្គហេតុ ព្រោះវាពិតជាមិនបានឆ្លុះបញ្ចាំងស្ថានភាពដ៏គួរឱ្យរន្ធត់នៅក្នុងទីក្រុងភ្នំពេញក្នុង ខែ មេសា ឆ្នាំ១៩៧៥ ឡើយ[51]។ មានការបញ្ជាក់យ៉ាងច្បាស់ថាជីវិតនៅក្នុងទីក្រុងភ្នំពេញ គឺមានសភាពគួរឱ្យរន្ធត់រួចទៅហើយនៅពេលដែលមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានមកកាន់កាប់ទីក្រុងនេះ ហើយបញ្ហាដ៏គួរឱ្យរន្ធត់នេះ បានកើតឡើងទាក់ទងនឹងសេវាសុខភាព និងស្បៀងអាហារ។ ប៉ុន្តែ កសចស បែរជាប្រើពាក្យដែលមានន័យស្រាលជាងនេះទៅវិញដូចជាពាក្យថា "ចំនួនអ្នកផ្តល់សេវាសុខាភិបាល និងមន្ទីរពេទ្យមានការធ្លាក់ចុះ" "គុណភាពនៃសេវាសុខាភិបាលមានការប្រែប្រួល" ភាពអត់ឃ្លាន និងការខ្វះអាហាររូបបត្ថមគឺជាបញ្ហាដែលត្រូវបារម្ភ" ជាដើម ជាជាងប្រើពាក្យថាមានភាពអាសន្នជាច្រើនដែលតម្រូវឱ្យមានជំនួយផ្នែកមនុស្សធម៌នៅពេលនោះ។ លោក នួន ជា ត្រូវតែទទួលបានឱកាសដើម្បីជំទាស់ទៅនឹងទស្សនរបស់ កសចស និងដើម្បីផ្តល់ភស្តុតាងគាំទ្រឱ្យបានសមរម្យចំពោះការអះអាងរបស់គាត់ទាក់ទងនឹងកាលៈទេសៈដ៏គួរឱ្យរន្ធត់ក្នុងទីក្រុងភ្នំពេញក្នុង ខែមេសា ឆ្នាំ១៩៧៥។

*ខ.ការខកខានរបស់ កសចស ក្នុងការពិភាក្សាពីការទម្លាក់គ្រាប់បែករបស់អាមេរិក*

៣៤. ការបង្ហាញឱ្យឃើញដ៏ទៃទៀតនៃការខកខានរបស់ កសចស ក្នុងការស៊ើបអង្កេតធាតុផ្សំបរិបទពាក់ព័ន្ធ ត្រូវបានគេមើលឃើញតាមរយៈការសង្កេតដែលថាដីកាដំណោះស្រាយមិន

---

[51] មានហេតុផលជាដុំកំភួន (ដែលផ្អែកលើហេតុផលនេះលោក នួន ជា ចង់ធ្វើការពន្យល់បន្ថែមតាមរយៈការស្តាប់ សក្ខីកម្មសាក្សី) ដើម្បីធ្វើការសន្និដ្ឋានថាជីវិតនៅក្នុងទីក្រុងភ្នំពេញ គឺមានលក្ខណៈគួរឱ្យរន្ធត់នៅពេលដែលមេដឹកនាំកម្ពុជាប្រជាធិបតេយ្យឡើងកាន់កាប់ទីក្រុងនេះ ហើយបញ្ហាដ៏គួរឱ្យសង្វេកនេះទាក់ទងនឹងស្បៀងអាហារ និងសេវាសុខាភិបាល។ ប៉ុន្តែ កសចស បែរជាងាកទៅប្រើពាក្យដែលមានន័យស្រាលជាងនេះទៅវិញដូចជាពាក្យថា "បុគ្គលិក និងគ្រឿងបរិធាននៃសេវាសុខាភិបាលបានធ្លាក់ចុះសមត្ថភាពនៅអំឡុងពេលនោះ។ មន្ទីរពេទ្យក្នុងរាជធានីកាន់តែមានសភាពណែនតាន់តាប់ និងគុណភាពមានការប្រែប្រួល" ភាពអត់ឃ្លាន និងការខ្វះអាហាររូបបត្ថមគឺជាបញ្ហាដែលត្រូវបារម្ភ" ជាដើម ជាជាងប្រើពាក្យថាមានភាពអាសន្នជាច្រើនដែលតម្រូវឱ្យមានជំនួយផ្នែកមនុស្សធម៌នៅពេលនោះ។ ដីកាដំណោះស្រាយកថាខណ្ឌ ២២២ ដល់ ២២៣ , លោក នួន ជា ត្រូវតែទទួលបានឱកាសដើម្បីជំទាស់ទៅនឹងទស្សន របស់ កសចស និងដើម្បីផ្តល់ភស្តុតាងគាំទ្រឱ្យបានសមរម្យចំពោះការអះអាងរបស់គាត់ទាក់ ទងនឹងកាលៈទេសៈដ៏គួរឱ្យរន្ធត់ក្នុងទីក្រុងភ្នំពេញក្នុង ខែ មេសា ឆ្នាំ១៩៧៥។

បានលើកឡើងអ្វីទាំងអស់អំពីយុទ្ធនាការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកលើប្រទេសកម្ពុជាក្នុងទសវត្សស៦០ និងដើមទសវត្សរ៍៧០។ វាស្ទើរតែមិនគួរឲ្យជឿ ព្រោះគ្មានពាក្យណានៅ ក្នុងដីកាដំណោះស្រាយបានលើកឡើងពីប្រភពនៃយុទ្ធនាការទម្លាក់គ្រាប់បែបនេះ គោលបំណងពិតប្រាកដរបស់វា ឥទ្ធិពលរបស់វាដោយផ្ទាល់ទៅលើការស្លាប់ប្រជាជនស៊ីវិល ឥទ្ធិពលរបស់វាទៅលើការខូចខាតហេដ្ឋរចនាសម្ព័ន្ធ ឥទ្ធិពលរយៈពេលខ្លី និងរយៈពេលវែងរបស់វាទៅលើការរក្សាទុកស្បៀង និងការផលិតស្បៀង ការធ្វើឲ្យរបួសដល់សមាជិកច្រើនរាប់មិនអស់នៃកម្លាំងផលិត ការធ្វើឲ្យមានជនភៀសខ្លួនរាប់លាននាក់ ឥទ្ធិពលផ្នែកចិត្តសាស្ត្រយ៉ាងធ្ងន់ធ្ងរលើអ្នករស់រានជិវិត ឬឥទ្ធិពលនយោបាយដ៏ធំធេងរបស់យុទ្ធនាការទម្លាក់គ្រាប់បែកនេះ។

៣៥. តាមទស្សនវិស័យច្បាប់ សម្រាប់មូលហេតុដែលបានផ្តល់ឲ្យខាងលើ វាសុទ្ធតែជា ប្រធានបទពាក់ព័ន្ធទាំងអស់ដែលត្រូវធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវ[52]។ប៉ុន្តែដីកាដំណោះស្រាយមិនបានលើកឡើងសូម្បីតែការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ឬឥទ្ធិពលរបស់វាឡើយ។ បើពិចារណាទៅលើការខូចខាតដ៏ធំធេងដែលបណ្តាលមកពីការទម្លាក់គ្រាប់បែកនេះ (និងឥទ្ធិពលដ៏មហន្តរាយរយៈពេលវែងរបស់វាទៅលើសង្គមកម្ពុជាទាំងមូល) និងភាពពាក់ព័ន្ធដែលស្តែងចេញឲ្យឃើញអំពីការប៉ះពាល់ដល់បញ្ហាដែលជាប្រធានបទក្នុងសំណុំរឿង០០២ ការខកខានបែបនេះគឺមិនអាចអត់អោនឲ្យបានឡើយ។ដើម្បីឲ្យកាន់តែច្បាស់ផែនទីពណ៌អំពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ត្រូវបានដាក់ភ្ជាប់មកជាឧបសម្ព័ន្ធដើម្បីគូសបញ្ជាក់ពីវិសាលភាពនៃការទម្លាក់គ្រាប់បែកនេះ។ វាបង្ហាញពីភាពពាក់ព័ន្ធមួយក្រឡេកភ្នែក *(Prima facie)* នៃយុទ្ធនាការទម្លាក់គ្រាប់បែកដែលបណ្តាលឲ្យកើតមានបញ្ហាមួយចំនួនដែលបង្កើតបានជាផ្នែកដ៏សំខាន់នៃសំណុំរឿង ០០២ (ដូចជាការបំផ្លាញសមត្ថភាពផលិតស្បៀង និងហេដ្ឋារចនារម្ព័ន្ធទូទៅ)[53]ជាដើម។ សម្រាប់មូលហេតុដែលបានផ្តល់ឲ្យពីខាងលើ លោក

---

[52] គេមិនអាចកាត់ផ្តាច់សម័យកម្ពុជាប្រជាធិបតេយ្យចេញពីការទម្លាក់គ្រាប់បែករបស់អាមេរិកឡើយ។ បញ្ហាទាំងពីរ នេះមានទំនាក់ទំនងនឹងគ្នាជាប្រវត្តិសាស្ត្រ។ វានឹងមិនមែនជាការចង់បានទាល់តែសោះឡើយក្នុងការពិភាក្សាអំពី "សវតារប្រវត្តិសាស្ត្រ" នៃរបបកម្ពុជាប្រជាធិបតេយ្យដោយមិនបានលើកឡើងពីការទម្លាក់គ្រាប់បែករបស់អាមេរិក។

[53] ឧបសម្ព័ន្ធ I។

នួន ជា ត្រូវបានទួលបានការអនុញ្ញាតឲ្យផ្តល់ភស្តុតាងបញ្ជាក់ពីឥទ្ធិពលរយៈពេលវែងនៃការទម្លាក់គ្រាប់បែកបស់អាមេរិក និងឥទ្ធិពលភ្លាមៗរបស់វាជាផ្នែកមួយនៃការការពារក្តីរបស់គាត់។

## ២. ដូចគ្នានេះដែរ កសព ក៏ខកខានមិនបានស៊ើបអង្កេតដែរ

៣៦. ដូចគ្នានេះដែរ កសព បានមើលរំលងបញ្ហាទាក់ទងនឹងបរិបទសំខាន់ៗ។ គេអាចសន្និដ្ឋានលើករណីនេះបានដោយគ្រាន់តែក្រឡេកមើលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរខកខានមិនបានលើកឡើងពីស្ថានភាពដ៏គួរឲ្យរន្ធត់នៅក្នុងប្រទេសកម្ពុជា និងក្នុងទីក្រុងភ្នំពេញនៅមុនឆ្នាំ១៩៧៥ ឡើយ។ ជាមួយគ្នានេះដែរ យុទ្ធនាការទម្លាក់គ្រាប់បែករបស់អាមេរិក ក៏មិនត្រូវបានលើកឡើងដែរ។

## ៣. មេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យស៊ើបអង្កេត កសចស មិនធ្វើការស៊ើបអង្កេតឲ្យមេធាវីការពារក្តី

៣៧. ម្យ៉ាងវិញទៀតមេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យធ្វើការស៊ើបអង្កេតដោយឯករាជ្យស្របតាមការណែនាំយ៉ាងច្បាស់លាស់ពី កសចស[54]។ ដោយសារហេតុផលនេះ មេធាវីការពារក្តីបានស្នើសុំយ៉ាងច្បាស់លាស់ជាច្រើនលើកច្រើនសារឲ្យ កសចស ធ្វើការស៊ើបអង្កេត ទៅលើបញ្ហាបរិបទដ៏ទូលំទូលាយជូនមេធាវីការពារក្តី[55]។ សំខាន់ជាងនេះទៅទៀត កសចស ខកខានមិនបានស្នើសុំកិច្ចស៊ើបសួរទៀតផង។ កសចស បានបដិសេធយ៉ាងដាច់អហង្ការការ

---

[54] សូមមើល A110/1 លិខិតរបស់ កសចស ទៅកាន់ក្រុមមេធាវីការពារក្តីលោក នួន ជា, ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨, ERN 00157730។

[55] សូមមើលសំណើសុំបំពេញកិច្ចកិច្ចស៊ើបសួរទី១២ និងទី៥ របស់លោក នួន ជា ។ ឧទាហរណ៍ ក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរទី១២ មេធាវីការពារក្តីបានសរសេរថា "បើពីនិត្យមើលភាពចំបាច់ជាក់ស្តែងដើម្បីវាយតម្លៃពីទំហំនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងប្រទេសកម្ពុជានៅចន្លោះខែមេសា ឆ្នាំ១៩៧៥ និងខែមករា ឆ្នាំ១៩៧៩ ជាពិសេសឧក្រិដ្ឋកម្មដែលបណ្តាលមកពីភាព អត់ឃ្លាន និងការជម្លៀសដោយបង្ខំ គឺបណ្តាលមកពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ (ផ្ទុយពីកត្តាដៃទៀត) មេធាវីការពារក្តី ស្នើឲ្យ កសចស ធ្វើការស៊ើបអង្កេត..."។

នូវសំណើដ៏សមហេតុផលមួយចំនួនរបស់មេធាវីការពារក្តី ហើយ កសចស បានអះអាងថាខ្លួននឹងអនុវត្តតាមសំណើរបស់មេធាវីការពារក្តី ប៉ុន្តែតាមការពិត កសចស ខកខានមិនបានធ្វើដូច្នេះឡើយ[56]។ កថាខណ្ឌទី៣៨ ដល់៦០ នៃបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើសុំបំពេញកិច្ចស៊ើបសួរទី១២របស់មេធាវីការពារក្តី គឺជាការបង្ហាញយ៉ាងច្បាស់អំពីដំណោះស្រាយដែលមានកំហុសរបស់ កសចស ហើយត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធក្នុងសំណើនេះដើម្បីងាយស្រួលក្នុងការយោង[57]។

## *៤. សេចក្តីសន្និដ្ឋាន មេធាវីការពារក្តីមិនត្រូវបានគេទុកអ្វីឲ្យមាននៅក្នុងដៃឡើយ*

៣៨. ដោយសារតែការខកខានដោយ កសចស (និងពីមុននេះដោយ កសព) ក្នុងការអនុវត្តកិច្ចស៊ើបសួរដែលចាំបាច់ និងសមហេតុផលបំផុតទៅលើកាលៈទេសៈបរិបទ មេធាវីការពារក្តីមិនត្រូវបានគេទុកអ្វីឲ្យមាននៅក្នុងដៃឡើយនៅពេលនេះ។ សូម្បីតែសាក្សីដែលបានស្នើសុំដោយមេធាវីការពារក្តីក៏មិនត្រូវបានអនុញ្ញាតឲ្យផ្តល់សក្ខីកម្មដែរ ហើយឯកសារពាក់ព័ន្ធនិងគ្រប់គ្រាន់ក៏មិនត្រូវបានស្រាវជ្រាវ ឬរកឃើញដែរ។ ដោយសារតែការខកខានជាបន្តបន្ទាប់ដោយ កសព និង កសចស ក្នុងការស៊ើបអង្កេតឲ្យបានត្រឹមត្រូវអំពីបរិបទដ៏ទូលំទូលាយនៃរបបកម្ពុជាប្រជាធិបតេយ្យ សូម្បីតែនៅពេលដែលត្រូវបានស្នើសុំយ៉ាងទាន់ពេលវេលា និងច្បាស់លាស់ឲ្យធ្វើដូច្នេះដោយមេធាវីការពារក្តីក៏ដោយ ឥឡូវនេះមេធាវីការពារក្តី យល់ឃើញថា ខ្លួនត្រូវបានគេរាំងមិនឲ្យផ្តល់ភស្តុតាងគាំទ្រឲ្យបានសមស្របដល់ការអះអាងផ្នែកអង្គហេតុ និងអង្គច្បាប់របស់លោក នួន ជា ឡើយ។ ការមិនផ្តល់លទ្ធភាពឲ្យលោក នួន ជា

---

[56] ឧទាហរណ៍ នៅពេលពិចារណាពីសំណើទី១២របស់មេធាវីការពារក្តីសុំបំពេញកិច្ចស៊ើបសួរ កសចស បានបដិសេធមិនទាក់ទងគណៈកម្មាធិការកក្កបាទក្រហមអន្តរជាតិ និងមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីសុំព័ត៌មាន ពាក់ព័ន្ធទៅនឹងស្ថានភាពមុនឆ្នាំ១៩៧៥ ឡើយ។ ធ្ងន់ធ្ងរជាងនេះទៅទៀត កសចស នឹងទទួលយកផ្នែកខ្លះក្នុងសំណើនេះក្នុងការទាក់ទងរដ្ឋាភិបាលអាមេរិកដើម្បីសុំព័ត៌មានពាក់ព័ន្ធ ប៉ុន្តែតាមពិតទៅ កសចស មិនបានស្នើសុំ ព័ត៌មានទាក់ទងនឹងបរិបទទូលំទូលាយដូចដែលមេធាវីការពារក្តីបានស្នើសុំនោះទេ។ ផ្ទុយទៅវិញ កសចស បានស្នើសុំឲ្យផ្តល់ឲ្យនូវព័ត៌មាន*ដាក់បន្ទុក*។ (ក្នុងករណីណាក៏ដោយ សហរដ្ឋអាមេរិក មិនបានផ្តល់ព័ត៌មានតាមការស្នើសុំនេះទេ)។

[57] ឧបសម្ព័ន្ធ (អង្គបុរេជំនុំជម្រះមិនបានលើកឡើងពីសំណើទាំងនេះក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹង ឧទ្ធរណ៍ឡើយ ហើយក៏មិនទាន់ផ្តល់ហេតុផលឲ្យដឹងផងដែរ)។

បង្ហាញការការពារក្តីរបស់គាត់ប្រកបដោយប្រសិទ្ធិភាព គឺជាការរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ នៅក្នុងដំណាក់ កាលនេះ វាជាកតាព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវផ្តល់ដំណោះស្រាយមួយដែលមានប្រសិទ្ធិភាពដើម្បីដោះស្រាយការរំលោភបំពានខាងលើ។ មេធាវីការពារក្តីយល់ឃើញថាផ្នែកខ្លះនៃដំណោះស្រាយនេះត្រូវតែមានការស្តាប់សក្ខីកម្មសាក្សីដែលស្នើសុំដោយមេធាវីការពារក្តីដែលសក្សីទាំងនេះនឹងគាំទ្រដល់ការអះអាង និងការការពារក្តីដែលធ្វើឡើងដោយលោក នួន ជា[58]។

## V. សេចក្តីសន្និដ្ឋាន

៣៩. អាស្រ័យលើហេតុផលដែលបានផ្តល់ឲ្យក្នុងសំណើនេះ អង្គជំនុំជម្រះសាលាដំបូង គួរតែ :

ក) បន្តការពិភាក្សាលើផ្នែកប្រវត្តិសាស្ត្រនៃសវនាការវគ្គទីមួយ។

ខ) ស្តាប់សក្សីកម្មសាក្សី និងអ្នកជំនាញដែលបានស្នើសុំដោយមេធាវីការពារក្តី ដូចដែលបានលើកឡើងក្នុងក្នុងឯកសារលេខ E155.1.1 ស្តីពីប្រធានបទដែលលើកយកមកពិភាក្សាក្នុងកថាខណ្ឌ ១៥។

គ) ចាត់វិធានការខាងនីតិវិធីបន្ថែមទៀតដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងអាចវាយតម្លៃឲ្យបានត្រឹមត្រូវអំពីបរិបទប្រវត្តិសាស្ត្រដែលក្នុងនោះរបបកម្ពុជាប្រជាធិបតេយ្យប្រតិបត្តិកិច្ចការរបស់ខ្លួន រួមបញ្ចូលទាំង (ប៉ុន្តែមិនកំណត់ត្រឹម) ការទទួលយកឯកសារភស្តុតាងដែលពាក់ព័ន្ធទៅនឹងបញ្ហានេះ ក៏ដូចជាការផ្តល់ឱកាសដល់ភាគីទាំងអស់ធ្វើការអត្ថាធិប្បាយលើឯកសារទាំងនោះ។

ឃ) ស្តាប់សក្សីកម្មរបស់ជនជាប់ចោទស្តីពីប្រធានបទដែលបានលើកឡើងក្នុងកថាខណ្ឌ១៥ និង

---

[58] ជាជម្រើសមួយផ្សេងទៀត (ឬបន្ថែមពីលើនេះទៀត) អង្គជំនុំជម្រះសាលាដំបូង អាចសម្រេចឲ្យមានការស៊ើបអង្កេតបន្ថែមទៅលើប្រធានបទដូចដែលបានលើកឡើងក្នុងសំណើនេះស្របតាមវិធាន ៩៣ ប៉ុន្តែដោយពិចារណាឃើញថាការស៊ើបអង្កេតអាចត្រូវការពេលវេលាច្រើន មូលហេតុនៃសន្សំសំចៃខាងនីតិវិធី ហាក់បីដូចជាប្រឆាំងទៅនឹងដំណោះស្រាយនេះ។ បញ្ហានេះធ្វើឲ្យមានជម្រើសក្នុងការស្តាប់សក្សីកម្មរបស់សាក្សីដោយផ្ទាល់មាត់។

ង) អនុញ្ញាតឲ្យភាគីទាំងអស់ធ្វើការសន្និដ្ឋានដោយផ្ទាល់មាត់លើប្រធានបទដែលបានលើកឡើងក្នុងកថាខណ្ឌនេះ។

៤០. មុនពេលមានការសម្រេចណាមួយ និងដោយពិចារណាទៅលើសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលកំពុងរងការប៉ះពាល់ ទឡ្ហីករណ៍ផ្ទាល់មាត់ក្នុងសវនការជាសាធារណៈទាក់ទងនឹងសំណើនេះ គឺជាការត្រឹមត្រូវ និងត្រូវបានស្នើសុំ។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE